# ព្រះពុទ្ធ

................................ព្រះពុទ្ធ ( 563 – 483 មុន គ.ស).............................

....................(ដកស្រង់ពីសៀវភៅអរិយធម៌ខ្មែររបស់អ្នកស្រី ត្រឹង ងា)..................

កំណើត៖
-ព្រះពុទ្ធប្រសូត្រនៅថ្ងៃសុក្រ ១៥កើត ពេញបរមី ខែពិសាខ ឆ្នាំច នៅក្រោមដើមសាលព្រឹក្ស ក្នុងព្រៃលុម្ពិនីដែលស្ថិតនៅចំព្រំប្រទល់នៃនគរ កបិលពស្ដុ និងនគរ ទេវទហៈ។
-គេថាមានការអស្ចារ្យណាស់កើតឡើងមុននិងក្រោយពេលប្រសូត្រ។
-ប្រសូត្រ បានប្រាំថ្ងៃ ព្រាហ្មណ៍៨នាក់ថ្វាយព្រះនាមព្រះឱរសថា សិទ្ធាថ៌ ដែលមានន័យថា” អ្នកសំរេចប្រយោជន៍គ្រប់យ៉ាង” ហើយព្រាហ្មណ៍៧នាក់លើកម្រាមដៃពីរទាយថា “ បើព្រះកុមារ ស្ថិតនៅជាក្សត្រនឹងបានជាស្ដេចចក្រពត្តិ បើចេញសាងព្រះផ្នួសនឹងបានត្រាស់ជាព្រះពុទ្ធ” ប៉ុន្តែ ព្រាហ្មម្នាក់ទៀតឈ្មោះ កោណ្ឌញ្ញនៅក្មេងជាងគេ លើកតែម្រាមដៃមួយ ហើយទាយថាព្រះកុមារពិតជាបានត្រាស់ជាព្រះពុទ្ធមិនខាន ។

-៧ ថ្ងៃក្រោយពេលប្រសូត្រ ព្រះមាតាទ្រង់សោយទីវង្គត់ទៅកើតនៅឋានតុសិតឯព្រះកុមារក៏ត្រូវបានព្រះមាតុច្ឆារបស់ព្រះអង្គព្រះនាម មហាមច្ឆាមតិ គោមី បីបាច់ចិញ្ចឹមតមក។

ការត្រាស់ដឹង

-ព្រះជន្មបាន១៦ព្រះវស្សា ទ្រង់បានរៀបអភិសេកជាមួយព្រះនាងពិម្ពាយសោធរា។
-ព្រះបិតាបានចាត់អោយសង់ប្រាសាទបីថ្វាយព្រះអង្គ តម្រូវទៅតាមរដូវទាំងបី (ក្ដៅ-រងា-រំហើយ)។

ទេពនិម្មិតទាំងបួនយ៉ាង



ដោយអផ្សុកខ្លាំងពេកព្រះអង្គបានចេញទៅក្រសាលក្នុងឧទ្យានដែលស្ថិតនៅក្នុងបរមរាជវាំង។ក្នុងពេលចេញទៅក្រសាលទាំងបួនលើក ព្រះអង្គបានទតឃើញទេពនិម្មិត(ទេវតាចុះមកនិម្មិតខ្លួន) បួនយ៉ាង៖

-លើកទី១ ទតឃើញ មនុស្សជរា
-លើកទី២ ទតឃើញ មនុស្សឈឺ
-លើកទីបី ទតឃើញ មនុស្សស្លាប់
លើកទីបួន ទតឃើញ មនុស្សបួស។

-មនុស្សទាំងបួន
ប្រភេទនេះបានធ្វើអោយព្រះអង្គកើតក្ដីសង្វេគហើយយល់ច្បាស់អំពីបញ្ហាជីវិតរបស់សត្វលោក។មនុស្សប្រភេទទីបួនធ្វើអោយព្រះអង្គសោមនស្សចង់សាងផ្នួស។



ការសាងផ្នួស

-ក្នុងព្រះជន្ម ២៩ឆ្នាំ ព្រះសិទ្ធាថ៌ មានការនឿយណាយក្នុងជីវភាពរបស់ព្រះអង្គ ហើយមានសេចក្តីខ្ពើមរអើម លោកសន្និវាសនេះកាន់តែខ្លាំងឡើង។
-ព្រះអង្គសព្វព្រះរាជហប្ញទ័យចង់ដោះសាយ្របញ្ហាជីវិត ហើយចង់ជ្រើសរើសការសាងផ្នួសជាមធ្យោបាយ ដើម្បីសរេចនូវសម្មាសម្ពោធិញ្ញាណ។
-ទីបំផុត ព្រះអង្គលះបង់ព្រះរាជវង្ស ហើយលួចរត់ទៅសាងផ្នួសទាំងកណ្តាលរាត្រីស្ងាត់ ទោះបីព្រះបិតារារាំងគ្រប់មធ្យោបាយយ៉ាងណាក៏ដោយ។
-ក្រោយដែលបានដឹងថា ព្រះសទ្ធាថ៌ យាងទៅបួសក្នុងព្រៃមក កោណ្ឌញ្ញព្រាហ្មនិងកូនព្រាហ្មងទៀត៤នាក់ មានសទ្ធាជ្រះថ្លាទៅសាងផ្នួសដែរ ហើយតាមបំរើព្រះអង្គ។អ្នកបួសទាំង៥អង្គនេះហៅថា បញ្ចវគ្គិយ។
-ក្រោយពីបានសាកល្បងតបធម៌ជាមួយតាបស២នាក់(អ្នកបួសក្នុងសាសនាព្រាហ្ម)ឈ្មោះ អាឡារតាបស និង ឧទកតាបស ពុំបានលទ្ធផលល្អ ព្រះអង្គក៏ខំប្រឹងតស៊ូស្វែងរកសច្ចធម៌តែមួយព្រះអង្គឯងវិញ។



ការត្រាស់ដឹង

-ក្រោយពីធ្វើទុក្ករកិច្ច (កិច្ចដែលត្រូវបំពេញដោយលំបាក) អស់រយៈពេល៦វស្សាមក ព្រះអង្គបានយាងចាកចេញពី រាជគ្រឹះ(ធានីរដ្ឋមគធៈ) ធ្វើដំនើរទៅដល់ស្រុកពោធិគយា ក្នុងរដ្ឋមគធៈ។
-ព្រះអង្គទ្រង់តាំងសមាធិនៅក្រោមពោធិព្រឹក្សក្បែរស្ទឹង ទេរញ្ជរ ហើយទ្រង់បានផ្ចាញ់មារ។
-ព្រះអង្គបានត្រាស់ជាព្រះពុទ្ធនៅថ្ងៃ ពុធ ១៥កើត ពេញបរមី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម៣៥វស្សា។



ធម្មទេសនា
-លុះបានត្រាស់ដឹងនូវសម្មាសម្ពុធិញ្ញាណហើយ ព្រះពុទ្ធទ្រង់សំដែងធម្មទេសនាទូន្មានសត្វលោកដោយពុំប្រកាន់វណ្ណៈឡើយ។
-មនុស្សជាច្រើនបានចូលទៅសុះបួសរៀនក្នុងសំណាក់ព្រះអង្គ។
-ព្រះអង្គតែងបំពេញពុទ្ធកិច្ច៥ប្រការជានិច្ចអស់រយៈពេល៤៥ឆ្នាំ។-
_នៅពេលព្រឹក ទ្រង់និមន្តបិណ្ឌបាត្រ
_នៅពេលរសៀល ទ្រង់សំដែងធម្មទេសនាដល់សាធារណជន
_នៅពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ
_នៅពេលកណ្ដាលអាធ្រាត្រ ទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា
_នៅពេលជិតភ្លឺ ទ្រង់ប្រមើលទតនូវសត្វលោកដែលមានភ័ព្វ និងឥតភ័ព្វ។



បរិនិព្វាន

-ដល់ពេលចេញវស្សាទី៤៥ នៅថ្ងៃ១៥កើត ពេញបរមី ខែមាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ដាក់អាយុសង្ខាររបស់ព្រះអង្គ ដោយប្រាប់មារថាព្រះអង្គនឹងចូលបរិនិព្វានក្នុងរវាងបីខែទៀត។
-ពួកសាវ័កទាំងឡាយ ជាពិសេស អានន្ទ កាលបើបានដឹងថាព្រះអង្គបានកំរិតអាយុសង្ខារហួសទៅហើយ ពុំអាចកែប្រែបាន
ក៏សោយសោកយ៉ាងខ្លាំងស្ដាយព្រះពុទ្ធ។ព្រះអង្គមិនទាន់ចង់អោយព្រះពុទ្ធចូលបរិនិព្វានឡើយ។
-ព្រះអង្គយាងទៅដល់នគរ កុសិនារា ហើយទ្រង់យាងចូលទៅកាន់សាលវ័ន ហើយទ្រង់ត្រាស់អោយអានន្ទរៀបចំគ្រែថ្វាយព្រះអង្គផ្ទុំ (ផ្ទុំផ្អៀងទៅខាងស្ដាំព្រះបាទឆ្វេងត្រួតលើព្រះបាទស្ដាំ)។នៅមច្ឆិមរាត្រីព្រះអង្គទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា«ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតហៅអ្នកទាំងឡាយមកប្រាប់ថាអ្វីដែលកើតឡើងហើយ ដែលមានហើយ ដែលផ្សំផ្គុំហើយ តែងមានធម៌ភាពនឹងរលត់ទៅវិញជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងប្រយោជន៍អោយសំរេច ដោយកិរិយាមិនធ្វេសប្រហែសចុះ។»។ព្រះអង្គមានពុទ្ធដីកាតែប៉ុណ្ណោះ ទ្រង់ក៏រលត់សង្ខារនៅពេលនោះទៅ។
-ព្រះពុទ្ធចូលបរិនិពាន្វ នៅថ្ងៃអង្គារ ១៥កើត ពេញបរមី ខែពិសាខ ឆ្នាំម្សាញ់ ៥៤៣ មុន គ.ស ក្នុងព្រះជន្ម ៨០វស្សា។

